**Declassified to Public**
**06 September 2012**

ᏟᏐᏃ/ᏁᎸ-A75

# សូមគោរពជូន
## លោកសហចៅក្រម យូ ប៊ុនឡេង និង Marcel LEMONDE

សំណុំរឿងស៊ើបអង្កេតលេខ: ០០១/១៨-០៧-២០០៧

កម្មវត្ថុ: សំណើសុំការផ្តល់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាភាសាបារាំង

យើងខ្ញុំ ដែលមានឈ្មោះដូចខាងក្រោមគឺ មេធាវី ការ សាវុត្ថ និង មេធាវី François ROUX ជាមេធាវីរបស់លោក កាំង ហ្គេកអ៊ាវ មានកិត្តិយសសូមអញ្ជើញលោកសហចៅក្រមសូមលោកមេត្តាផ្តល់ឱ្យយើងខ្ញុំនូវកំណត់ហេតុជាភាសាបារាំងនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានរាយនាមដូចខាងក្រោម:

- ប្រាក់ ខន
- សួស ធី
- គង់ ផៃ
- ម៉ម ណៃ
- តយ តេង
- វ៉ាន់ ណាត
- សោម ម៉េត
- ទ្រី ឃន
- ឈុន ផល
- មាស ប៉េងគ្រី
- ជុំ ម៉ី (ដើមបណ្តឹងរដ្ឋប្បវេណី)
- ប៊ូ ម៉េង (ដើមបណ្តឹងរដ្ឋប្បវេណី)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 02 / 2008
ម៉ោង (Time/Heure): 14 : 30 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 20 / 02 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KOSAL

mAIN·A75

យើងខ្ញុំប្រាថ្នាចង់បាននូវលទ្ធភាពនឹងពិនិត្យមើលឯកសារទាំងអស់នេះជាភាសាបារាំងក្នុងរយៈពេលមួយយ៉ាងឆាប់រហ័សដើម្បីអាចឲ្យយើងខ្ញុំរៀបចំត្រៀមនូវការសួរតទល់គ្នាដែលនឹងកើតមានឡើងរវាងលោក កាំង ហ្កេកអ៊ាវ និង សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានរៀបរាប់ដូចខាងលើ ក្នុងការចុះទៅពិនិត្យដល់កន្លែងកើតហេតុ និងក្នុងការសួរតទល់គ្នានៅថ្ងៃទី ២៦, ២៧, ២៨ និង ២៩ ខែកុម្ភៈ ឆ្នាំ ២០០៨ ។

ម្យ៉ាងវិញទៀត យើងខ្ញុំសូមឲ្យលោកសហចៅក្រមមេត្តាផ្តល់ដល់យើងខ្ញុំនូវកំណត់ហេតុជាភាសាបារាំងនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀតដែលត្រូវបានស្តាប់ហើយរហូតមកដល់បច្ចុប្បន្ននេះ ដោយអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងក្របខណ្ឌនៃសំណុំរឿងស៊ើបអង្កេតនេះ ។

សូមលោកសហចៅក្រមមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១៩-០២-២០០៨

មេធាវី ការ សាវុត្ថ　　　　មេធាវី François ROUX